**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ៤៣៥ ពណ.ចបក

ថ្ងៃ [illegible] ខែ កត្តិក ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ ធ្នូ ឆ្នាំ ២០១៨

# សេចក្តីបញ្ជាក់បន្ថែម
## ស្តីពីការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តកម្ម

ក្រសួងពាណិជ្ជកម្ម សូមជម្រាបជូនឧកញ៉ា លោក-លោកស្រី ដែលជាអ្នកគ្រប់គ្រងក្រុមហ៊ុនទាំងអស់ឲ្យបានជ្រាបថា ដោយយោងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម និងប្រកាសលេខ១០៧ ព.ណ.ចបព.ប្រក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៧ ស្តីពីការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ក្រុមហ៊ុនទាំងអស់ដែលបានចុះបញ្ជីពាណិជ្ជកម្មរួច ត្រូវមានកាតព្វកិច្ចតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំជារៀងរាល់ឆ្នាំ។

ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន គឺត្រូវចាប់ផ្តើមធ្វើជារៀងរាល់ឆ្នាំនៅថ្ងៃខួបនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុននីមួយៗ ហើយការតម្កល់នេះមានរយៈពេលកំណត់៣ខែក្រោយថ្ងៃខួបរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនត្រូវធ្វើការតម្កល់ដោយខ្លួនឯង តាមរយៈគេហទំព័រ ww.businessregistration.moc.gov.kh ដោយបង់កម្រៃសេវាសាធារណៈចំនួន ៨០,០០០ រៀល (ប្រាំបីម៉ឺនរៀល)។ ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្មនេះ គឺមិនត្រូវរង់ចាំការត្រួតពិនិត្យឬទទួលយល់ព្រមពីមន្ត្រីក្រសួងពាណិជ្ជកម្មនោះឡើយ។

ដើម្បីជៀសវាងការខកខានក្នុងការបំពេញកាតព្វកិច្ចក្នុងការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុននីមួយៗ ប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្មបានធ្វើការជូនដំណឹងរំលឹកដោយស្វ័យប្រវត្តដល់ឧកញ៉ា លោក-លោកស្រី ដែលជាអ្នកគ្រប់គ្រងក្រុមហ៊ុនទាំងអស់ជាសារអេឡិចត្រូនិច (E-mail) ទៅកាន់អាសយដ្ឋានសារអេឡិចត្រូនិច (E-mail Address) របស់ឧកញ៉ា លោក-លោកស្រី ដែលមាននៅក្នុងប្រព័ន្ធ។ ការជូនដំណឹងរំលឹកនេះ គឺធ្វើឡើងចំនួន ០៤ដង ដែលមានរយៈពេល០៤ខែ។ សារលើកទី១គឺធ្វើការជូនដំណឹង១ខែមុនដល់ថ្ងៃខួបក្រុមហ៊ុន ហើយសារលើកទី២ដល់លើកទី៤ ជាការរំលឹករៀងរាល់៣០ថ្ងៃម្តងក្នុងអំឡុងពេល៣ខែដែលត្រូវតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ។

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone / Facsimile: (855)-23 866 469

ក្រសួងពាណិជ្ជកម្ម សូមបញ្ជាក់ជូនថា ក្នុងករណីក្រុមហ៊ុនបានផ្តល់អាសយដ្ឋានសារអេឡិចត្រូនិច មិនត្រឹមត្រូវ ឬមិនច្បាស់លាស់ក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម គឺជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនចំពោះការខកខានក្នុងការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ។

ក្នុងករណីក្រុមហ៊ុនមិនបានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមកាលកំណត់ ក្រុមហ៊ុននឹងត្រូវទទួលពិន័យជាប្រាក់ចំនួន ២,០០០,០០០ រៀល (ពីរលានរៀល) ដែលបានកំណត់នៅក្នុងប្រកាសរួមលេខ ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ រវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

លើសពីនេះទៅទៀត ក្រសួងពាណិជ្ជកម្មបានធ្វើសេចក្តីជូនដំណឹង ផ្សព្វផ្សាយដល់ឧកញ៉ា លោក-លោកស្រី តាមគ្រប់រូបភាពរួមមាន ការធ្វើសិក្ខាសាលាជាច្រើនលើកតាមបណ្តាខេត្ត-រាជធានី ការចុះផ្សាយជាសេចក្តីជូនដំណឹងតាមគេហទំព័រចុះបញ្ជីពាណិជ្ជកម្ម គេហទំព័រក្រសួងពាណិជ្ជកម្ម Facebook ក្រសួងពាណិជ្ជកម្មជាដើម។

អាស្រ័យដូចបានបញ្ជាក់ជូនខាងលើនេះ សូមឧកញ៉ា លោក-លោកស្រីជ្រាបជាព័ត៌មាន។